**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៤៩/២០២៦ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

## ការធ្វើបទបង្ហាញជូនអង្គទូតអំពីការអនុម័តច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលរៀបចំការធ្វើបទបង្ហាញជូនអង្គទូត និងអង្គការអន្តរជាតិប្រចាំកម្ពុជា អំពីច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលបានចូលជាធរមានកាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦។ បទបង្ហាញនេះត្រូវបានដឹកនាំដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី ផៃ ស៊ីណារិទ្ធ ប្រធានលេខាធិការដ្ឋានគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

ឯកឧត្តមទេសរដ្ឋមន្ត្រី ផៃ ស៊ីណារិទ្ធ បានសម្តែងការកោតសរសើរដល់ស្ថានបេសកកម្មបរទេស និងដៃគូទាំងអស់ ចំពោះការបន្តកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន។ ឯកឧត្តមបានគូសបញ្ជាក់អំពីការកើនឡើងនៃភាពស្មុគស្មាញ នៃការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលលាតសន្ធឹងហួសពីព្រំដែនប្រទេស ក៏ដូចជាធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ លើសន្តិសុខសាធារណៈ និងកេរ្តិ៍ឈ្មោះប្រទេសជាតិ។ ឯកឧត្តមបានធ្វើការពន្យល់អំពីការបង្ក្រាបជាបន្តបន្ទាប់នៅទូទាំងប្រទេស ដឹកនាំដោយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលបាននាំមកនូវលទ្ធផលសំខាន់ៗ ព្រមទាំងបានសង្កត់ធ្ងន់លើសារៈសំខាន់ និងភាពពាក់ព័ន្ធនៃច្បាប់ថ្មីដែលទើបតែអនុម័ត។ ច្បាប់ថ្មីនេះដាក់ទោសទណ្ឌយ៉ាងតឹងរ៉ឹងចំពោះជនល្មើស និងជាឧបករណ៍គ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពមួយ សម្រាប់អាជ្ញាធរអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានអះអាងថា ការអនុវត្តច្បាប់ថ្មីនេះនឹងមានភាពរឹងមាំ មានតម្លាភាព និងស្របតាមនីតិវិធីត្រឹមត្រូវ ព្រមទាំងធានាបាននូវការការពារពេញលេញក្រោមច្បាប់នេះសម្រាប់អ្នកដែលសហការជាមួយអាជ្ញាធរ ក៏ដូចជាជនរងគ្រោះពិតប្រាកដ និងម្ចាស់អចលនទ្រព្យស្លូតត្រង់ផងដែរ។ ឯកឧត្តមបានពន្យល់អំពីបញ្ហាប្រឈមផ្នែកបច្ចេកទេសជាច្រើន ដែលប្រទេសកម្ពុជាកំពុងប្រឈម និងបានគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីដោះស្រាយវិធីសាស្ត្រឧក្រិដ្ឋកម្ម ដែលកំពុងវិវត្ត រួមមាន ការប្រើប្រាស់បញ្ញាសិប្បនិម្មិត ប្រព័ន្ធកូដនីយកម្ម (encrypted platforms) កម្មវិធីសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុខុសច្បាប់ឆ្លងដែន និងគម្រោងវិនិយោគក្លែងបន្លំ ជាដើម។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ឯកឧត្តមទេសរដ្ឋមន្ត្រី ឆៃ ស៊ីណារិទ្ធ បានបញ្ជាក់ជាថ្មីថា ការប្រយុទ្ធប្រឆាំងការឆបោកដែលផ្អែកលើប្រព័ន្ធបច្ចេកវិទ្យានេះនៅតែជាអាទិភាពចម្បង សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ហើយឯកឧត្តមក៏បានសម្តែងនូវទំនុកចិត្តថា ដោយមានកិច្ចសហប្រតិបត្តិការអន្តរជាតិពេញលេញ ប្រតិបត្តិការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានឹងត្រូវលុបបំបាត់ទាំងស្រុងពីប្រទេសកម្ពុជា។ ឯកឧត្តមបានស្នើឱ្យដៃគូអន្តរជាតិជួយបន្តការគាំទ្រផ្នែកកសាងសមត្ថភាព ជំនួយបច្ចេកទេស ការចែករំលែកព័ត៌មាន និងកិច្ចខិតខំប្រឹងប្រែងរួមក្នុងការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្លួន។ ការធ្វើបទបង្ហាញបានបិទបញ្ចប់ដោយវគ្គសំណួរ-ចម្លើយ៕

ថ្ងៃពុធ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦